ការញញឹមខ្មែរ

ការញញឹមខ្មែរ ធ្លាប់មានកេរ៍្តឈ្មោះជាទេសចរណ៍។ ដូចជា ស្រ្តីទេពអប្សរ លើផ្ទាំងសិលា នៃប្រាសាទបុរាណខ្មែរ ផ្សព្វផ្សាយ នូវស្នាមញញឹម នៅក្នុងបរិយាការណ៍ឧទ្យាន ជាសិប្បនិម្មិតស្រមុតចិត្ត សំរាប់អ្នកទេសចរណ៍គ្រប់សញ្ជាតិ ដែលបានមកទស្សនា។ មែនពិតហើយ នៅក្នុងជីវិតប្រចាំថ្ងៃ រាស្រ្តខ្មែរ តែងតែយក នូវការញញឹម ជាចម្លើយ នៃភាពអៀនបៀនរបស់ខ្លួន។ ដោយកម្រ គេបានទទួលចម្លើយ ចំពោះសំនួរទីមួយ ពីបថុជ្ជនខ្មែរ លើកលែងតែស្នាមញញឹមរបស់គាត់។ ជាទូទៅ ស្នាមញញឹមខ្មែរ ជាភាសា-គ លាក់នូវ សេចក្តីរីករាយផង ភាពទុក្ខព្រួយផង ការភ័យខ្លាចផង នៅចំពោះមុខតម្បៀត នៃអំណាចគ្រប់បែបយ៉ាង រួមទាំងអំណាចមេបា។ វាជាការអប់រំខ្មែរ ឲ្យមានចរិយាស្លូតបូតអកម្ម ទើបទុកជាមនុស្សល្អ។ ដូច្នេះ មនុស្សល្អខ្មែរ ជាន្ទួនល្អុង រស់នៅក្នុងសំណាក់ នៃទំនាមដោយបន្ទាំ ដែលមានការញញឹម ជាផ្នែកមួយ នៃផ្ទៃមើលឃើញ។ ការសម្តែងមនោសញ្ចោតនា លើភក្រ្តតាមការញញឹមនេះ បញ្ជាក់ នូវរបួសនៃជម្ងឺផ្លូវចិត្ត បណ្តាលមកពីខ្លាចអំណាច ពង្វឹកចិត្ត តាំងពីដឹងក្តី។ ដូច្នេះ ស្នាមញញឹមខ្មែរ មានទិដ្ឋភាពពីរយ៉ាង មួយមានពីជម្មជាតិ នៃមនុស្ស មួយទៀត កើតមកពីទណ្ឌកម្ម ដែលត្រូវបន្ទេរ នូវកាយ និង ចិត្ត ពេញមួយជីវិត។ ដូច្នេះ ជានឹម នៃសោភ័ន នៃបបូរមាត់ និង សេចក្តីក្តុកក្តួលអួលចិត្ត នឿយណាយក្នុងអារម្មណ៍។ ទុំះទំ ជារឿងបរមត្ថ នៃការញញឹមខ្មែរ៕

ឧប សៅ សង្ហា　　　　　កំនិត　　　　　២០ មិថុនា ២០១៩